ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# នីតិព្រហ្មទណ្ឌ
# នៃព្រះរាជាណាចក្រកម្ពុជា

## ការសើបអង្កេត
## តាមក្រមនីតិវិធីព្រហ្មទណ្ឌ

វ៉ាត ចន្ថា

រដ. ភ្នំពេញ

គ.ស. ២០១៧

របាយការណ៍លេខ០១ ចេញ

ឆ្នាំ២០១៧

# ជំពូកទី១

# ការស៊ើបអង្កេត

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

### កថាខ័ណ្ឌទី១៖ ការសម្គាល់នៃការស៊ើបអង្កេត

ដោយអនុលោមតាមមាត្រា៨៣ រហូតដល់មាត្រា៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ បានប្បញ្ញត្តិទាក់ទងនឹងការសម្គាល់ នៃមន្ត្រីដែលមានភារកិច្ចរក្សាការសំងាត់ដោយមូលហេតុគាត់ជាមន្ត្រី ឬ អ្នកប្រកបវិជ្ជាជីវៈសេរីមានដូចជាចៅក្រមខាងអាយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដទៃទៀត។

ក្រៅពីមន្ត្រីរាជការ និងបុគ្គលដូចបានរៀបរាប់ខាងលើក៏មានបុគ្គមួយប្រភេទដែលគេឱ្យងារគាត់ជាមន្ត្រីបច្ចេកទេសតាមរយៈមាត្រា១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) និងបុគ្គលដែលមានសមត្ថកិច្ចជាអ្នកបច្ចេកទេសតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ដូចក្នុងមាត្រា៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**ក. មន្ត្រីក្នុងបញ្ជីអ្នកជំនាញ**

ដោយអនុលោមតាមមាត្រា១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្នុងករណីដែលមានបញ្ហាបច្ចេកទេសបានចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញានៃជនត្រូវ

ចោទ ឬ ដោយដើមបណ្ដឹងរដ្ឋប្បវេណី។ ករណីនេះចៅក្រមស៊ើបសួរអាចឱ្យ ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌តាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយអនុលោមតាមមាត្រា១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដើម្បីជ្រើសរើសយកបុគ្គលដែលជាអ្នកបច្ចេកទេសពីបញ្ជីអ្នកជំនាញដែលបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលកំណត់ពីនីតិវិធីដើម្បីទទួលបានងារជាអ្នកជំនាញក្នុងបញ្ជីរបស់ក្រសួងយុត្តិធម៌ ដែលនឹងមានបកស្រាយបន្តនៅក្នុងគន្ទីទី៩ ការស៊ើបសួរ។

### ខ. អ្នកជំនាញមានសមត្ថកិច្ចតាមមន្ត្រីនគរបាលយុត្តិធម៌

លើសពីនេះក្នុងករណីដែលមានស្ថានការបន្ទាន់ដែលចាំបាច់ឱ្យមានអ្នកជំនាញ ឬ អ្នកបច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ប៉ុន្តែតម្រូវឱ្យបុគ្គលនេះស្បថតាមជំនឿសាសនារបស់ខ្លួនថានឹងជួយដោយភក្ដីភាពដល់តុលាការ។

បើទោះជាមានការរក្សានូវការសម្ងាត់ពីសំណាក់មន្ត្រីដែលមានសមត្ថកិច្ច ឬ អ្នកជំនាញ ឬ បុគ្គលដែលពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏ច្បាប់បើកឱ្យមានការប្រើប្រាស់សិទ្ធិការពារខ្លួនពីសំណាក់បុគ្គលនេះចំពោះការចោទប្រកាន់ដែលគ្មានមូលដ្ឋាន ឬ ក៏ការសម្ងាត់ដែលត្រូវបានបែកធ្លាយនោះមិនមែនជាព័ត៌មានដែលពិត ឬ ក្នុងករណីដែលមានការពាក់ព័ន្ធនឹង ការចោទប្រកាន់ណាមួយ ដែលតម្រូវឱ្យមានការទំលាយនូវការសម្ងាត់នេះ ដើម្បីជាផលប្រយោជន៍សម្រាប់ការពារខ្លួនរបស់បុគ្គលដែលត្រូវបានចោទប្រកាន់នៅក្នុងករណីខ្លះ។ ឧទាហរណ៍៖ វេជ្ជបណ្ឌិតម្នាក់គាត់បានធ្វើការវះកាត់ស្ត្រីម្នាក់ដើម្បីសម្រាលកូន ក្នុងន័យដើម្បីរក្សាឱ្យបាននូវជីវិតរបស់ទារក និងម្ដាយ។ ដោយហេតុការវះកាត់បរាជ័យ ដោយបណ្ដាលឱ្យម្ដាយដែលសំរាលកូននេះស្លាប់ ចំណែកឯទារកគឺមានជីវិត។ ដូច្នេះវេជ្ជបណ្ឌិតរូបនេះត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទមនុស្សឃាតដោយអចេតនាស្របតាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌជាធរមានបញ្ញត្តិ។ដើម្បីឱ្យរួចខ្លួន ឬអាចទទួលបាននូវស្ថានសម្រាលទោសវេជ្ជបណ្ឌិត

ចាំបាច់ត្រូវរៀបរាប់ពីគ្រប់ដំណាក់កាលទាំងអស់របស់អ្នកជម្ងឺ និងមូលហេតុជាសារវន្តនានា ដែលបណ្តាលឱ្យស្ត្រីនេះស្លាប់។

ការបង្ហាញនូវការសំងាត់នៃវិជ្ជាជីវៈដើម្បីការពារខ្លួនបែបនេះ គឺមិនត្រូវបានហាមឃាត់ និងទទួលបានការចោទប្រកាន់ដូចចំណុច ″គ″ ខាងក្រោមនេះទេ។

**គ. ការទទួលខុសត្រូវរបស់អ្នកទំលាយការសម្ងាត់**

ក្នុងករណីដែលមានការសម្ងាត់ខាងវិជ្ជាជីវៈ ឬ ការសំងាត់នានាដែលត្រូវបានបញ្ចេញ ដោយបុគ្គលណាមួយនោះបុគ្គលនោះនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់ជាធរមាន។ អនុលោម តាមមាត្រា៣១៤ (បទប៉ះពាល់ដល់អាថិកំបាំងខាងវិជ្ជាជីវៈ) នៃក្រមព្រហ្មទណ្ឌ២០០៩ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី០១ខែ ដល់០១ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន)រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

## កថាខ័ណ្ឌទី២៖ ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អនុលោមតាមមាត្រា៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាម ការស៊ើបអង្កេត) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អំណាចខុសគ្នា របស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងករណី នៃការស៊ើបអង្កេតបឋម។

# ជំពូកទី២

# ការស៊ើបអង្កេតករណីជាក់ស្តែង

## ផ្នែកទី១

## បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

### កថាខ័ណ្ឌទី១៖ និយមន័យទូទៅ

ដោយអនុលោមតាមមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) និង មាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គឺជាសកម្មភាពដែលជនល្មើសបានបង្កឡើងដោយស្ថិតក្នុងស្ថានភាពបួនគឺ៖

- បទល្មើសដែលកំពង់តែប្រព្រឹត្ត មានន័យថាជាសកម្មភាពដែលជនល្មើសកំពង់តែប្រព្រឹត្តដោយការមើលឃើញពីតតីយជន ឬ មន្ត្រីដែលអនុវត្តតែម្តងពីសកម្មភាពប្រព្រឹត្តបទល្មើសរបស់ជននោះ។
- បទល្មើសដែលប្រព្រឹត្តរួចភ្លាម មានន័យថាជាសកម្មភាពដែលបុគ្គលម្នាក់ដែលជាជនល្មើសបានប្រព្រឹត្តបទល្មើសណាមួយរួចរាល់ហើយ ហើយបានព្យាយាមគេចចេញពីកន្លែងកើតហេតុ ឬកំពង់តែនៅនឹងកន្លែងកើតហេតុពេលនោះត្រូវបានឃើញដោយតតីយជន ឬ មន្ត្រីដែលអនុវត្ត។

ក៏ត្រូវបានចាត់ទុកថាជនបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែរកាលណាក្រោយពេលប្រព្រឹត្តបទល្មើសរួចបន្តិចមក៖

- ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រផាប់ចាប់ប្រភីង មានន័យថា ជាជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើសមួយណានោះ ហើយបានរត់គេចខ្លួន ហើយត្រូវបានសាធារណៈជនកំពង់តែដេញចាប់ ស្រែកឱ្យចាប់ នៅខណៈពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទៅដល់ទីកន្លែងនោះ។
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុតាង ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលជាមូលដ្ឋានអាចឱ្យកំណត់បានថាជននេះបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើស។ មានន័យថាជាជនដែលនៅជិតកន្លែងកើតហេតុ ឬមិននៅនឹងកន្លែងកើតហេតុ ប៉ុន្តែនៅក្នុងថ្ងៃកើតហេតុត្រូវបានគេកំណត់ឃើញថាជននេះជាជនល្មើសដោយហេតុថាជននេះមានភស្តុតាង (Evidence) សាក្សី (Eyewitness) និងតម្រុយដែលស៊ីសង្វាក់នឹងបទល្មើស ហើយមានមូលដ្ឋានអាចសន្និដ្ឋានថាជននេះជាជនល្មើស (Suspect) ។

ដោយអនុលោមតាមមាត្រា ៨៨ (ការចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ក៏ចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះជាករណីនេះមិនដូចទៅនឹងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ក៏ដោយឱ្យតែអំពើនេះជា អំពើដែលបានប្រព្រឹត្តនៅកន្លែងដែលម្ចាស់កាន់កាប់នៅកន្លែងនោះសុំឱ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ចូលពិនិត្យ ឬ ឱ្យភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ករណីគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅកន្លែងនោះ។ ដោយភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌។ មានន័យថា នៅពេលដែលមានបទល្មើសមួយកើតឡើងនៅក្នុងលំនៅឋានរបស់ខ្លួន ឬទីតាំងរបស់ខ្លួន (រោងចក្រ សហគ្រាស កាដ្ឋានជាដើម)។ ក្នុងនាមជាម្ចាស់កន្លែង ឬលំនៅដ្ឋានអាចប្តឹងទៅកាន់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារមន្ត្រីនរគបាលយុត្តិធម៌ករណីដែលមិនមានមន្ត្រីនគបាលយុត្តិធម៌នៅជិតនោះដើម្បីឱ្យចូលពិនិត្យ ដើម្បីចាប់យកជនល្មើស និងវត្ថុតាងតាមពាក្យបណ្តឹងរបស់ម្ចាស់កាន់កាប់ទីកន្លែង។ ដោយហេតុថាម្ចាស់ទីកន្លែង ឬលំនៅឋានជាសាក្សីដ៏សំខាន់មួយ គួបផ្សំនឹងវត្ថុតាងដែលមាននៅទីនោះ

ស្រាប់ ឬដោយហេតុថាជាបទល្មើសជាក់ស្ដែងបុគ្គលណា ក៏អាចចាប់ជនបង្កបានដែរក្នុងលក្ខខណ្ឌនេះម្ចាស់ទីកន្លែងអាចចាប់ជនបង្កក្នុងទីកន្លែងរបស់ខ្លួនរងចាំព្រះរាជអាជ្ញា នគរបាលយុត្តិធម៌ ឬភ្នាក់ងារមន្ត្រីចូលមកចាប់ និងពិនិត្យ។ ហេតុអ្វីម្ចាស់ផ្ទះមិនចាប់ខ្លួនជនល្មើស និងវត្ថុតាងឱ្យមន្ត្រីនគរបាលយុត្តិធម៌ តែម្ដងទៅ? ដោយមូលហេតុថា ក្លាចម្ចាស់ផ្ទះទំលាក់កំហុសទៅលើបុគ្គលណាម្នាក់ថាជាជនល្មើសដោយសំអាងថាខ្លួនជាម្ចាស់ផ្ទះ និងសំអាងថាច្បាប់នីតិវិធិព្រហ្មទណ្ឌកម្ពុជាមិនបានប្រគល់សិទ្ធិឱ្យជនគ្រប់រូបអាចចាប់យកភស្តុតាង សាក្សី ឬកសាងសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញាទេនោះ។ ករណីដែលមានបុគ្គលណាមួយក្រៅពីមន្ត្រីនគរបាលយុត្តិធម៌ធ្វើការចាប់យកភស្តុតាង ឬឃាត់ខ្លួនសាក្សីជាអាទិ៍ វាជាហេតុនាំឱ្យមោឃកម្មនៃកិច្ចនីតិវិធីដូចទៅនឹងមាត្រា៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) មាត្រា៩៤(ការឃាត់ខ្លួន) និងមាត្រា១០៩ (មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ)ជាអាទិ៍នៃក្រនេះ។

## កថាខ័ណ្ឌទី២៖ ធាតុផ្សំកំណត់ជាបទល្មើសជាក់ស្ដែង

បើអនុលោមតាមមាត្រា១០៦ (ថេរវេលានៃការស៊ើបអង្កេតករណីជាក់ស្ដែង) ការស៊ើបអង្កេតលើករណីជាក់ស្ដែងគឺមានថេរវេលាស៊ើបអង្កេតគឺ៧ថ្ងៃបន្តគ្នាមិនដាច់។ ប៉ុន្តែបញ្ជាក់ជូនផងដែរថាការស៊ើអង្កេតដែលមានថេរវេលានេះ គឺក្នុងករណីជាបទល្មើសដែលមន្ត្រីនគរបាលបានសន្និដ្ឋានថាជាបទល្មើសជាក់ស្ដែង ហើយការស៊ើបអង្កេតនេះច្បាប់ឱ្យថេរវេលាចំនួន៧ថ្ងៃជាបទល្មើសជាក់ស្ដែង។ មូលហេតុដែលចាំបាច់ឱ្យមានការសន្និដ្ឋាន ឬកំណត់ពីបទល្មើសជាក់ស្ដែងនៅមុនពេលបើកការសើបអង្កេត ដោយសំអាងលើតម្រុយដូចទៅនឹងមាត្រា៨៦ (បទឧក្រិដ្ឋឬបទបជ្ឈឹមជាក់ស្ដែង)ឬមាត្រា៨៨(ចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) ចុះក្នុងកំណត់ហេតុស៊ើបអង្កេតជាមុន ព្រោះដើម្បីចុះពីកាលបរិច្ឆេទបើកការស៊ើបអង្កេតដើម្បីជាកំណត់ចំណាំលើថេរវេលានៃការស៊ើបអង្កេតនោះផងដែរ។ ករណីបន្ទាប់ពីការសន្និដ្ឋានថាជាបទល្មើសជាក់ស្ដែង ហើយបើកការស៊ើបអង្កេត ហើយនៅតែមិនអាចបញ្ចប់ការស៊ើអង្កេតទៀតនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែសុំយោបល់ព្រះរាជាអាជ្ញា។ ករណីនីតិវិធីនេះនឹងវិលមកជាការសើបអង្កេតបឋមដោយមន្ត្រីនគរបាលយុត្តិធម៌វិញ។

ថ្វីត្បិតតែបទល្មើសជាក់ស្តែងមិនមែនជាប្រភេទបទល្មើស ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែបទល្មើសជាក់ស្តែងជាការកំណត់ទៅលើសកម្មភាពរបស់ជនល្មើសដែលបានប្រព្រឹត្តទៅលើជនរងគ្រោះថាជាការប្រព្រឹត្តជាក់ស្តែង ឬ មិនជាក់ស្តែង។ ក្នុងករណីនៃបទល្មើសជាក់ស្តែងមានធាតុផ្សំចំនួនបីបន្ថែមពីលើ៤ចំណុចខាងលើមានដូចជា (១)វត្តមានជនល្មើស (២) វត្ថុតាង និង (៣)ការកំណត់របស់តតីជន ឬមន្រ្តីអនុវត្តជាបទល្មើសជាក់ស្តែង។ ក្នុងករណីមានតែអ្នកជនរងគ្រោះមិនមានជនល្មើសនៅកន្លែងកើតហេតុ ឬ មានតែជនរងគ្រោះ និងវត្ថុតាងមិនមានជនល្មើសនៅនឹងកន្លែងកើតហេតុ ក៏មិនអាចចាត់ទុកថាជាបទល្មើសជាក់ស្តែងបានដែរ។ ករណីដូច បុរស "ក" បានខ្ចីម៉ូតូរបស់លោក "ខ" ដើម្បីទៅទិញទឹកត្នោតជូរ។ អស់រយៈពេលបីថ្ងៃមិនឃើញយកមកឱ្យម្ចាស់ម៉ូតូវិញសោះ ដូច្នេះលោក "ខ" ជាម្ចាស់ម៉ូតូបានប្តឹងសមត្ថកិច្ច។ លុះដល់កន្លងមកបីថ្ងៃទៀតបានឃើញលោក "ក" នៅផ្ទះរបស់គាត់ដោយមិនមានម៉ូតូដែលជារបស់លោក "ខ" នោះទេ។ ករណីនេះមិនចាត់ទុកជាបទល្មើសជាក់ស្តែងទេដោយហេតុមិនមានវត្ថុតាងនៅជាមួយនឹងជនល្មើស។ ប៉ុន្តែករណីដែលឃើញម៉ូតូរបស់លោក "ខ" នៅនឹងកន្លែងលក់ម៉ូតូ ឬកន្លែងបញ្ចាំម៉ូតូ ឬ នៅផ្ទះលោក "ក" វិញនោះ ក៏មិនចាត់ទុកថាជាបទល្មើសជាក់ស្តែងដែរ។

ករណីដែលជាបទល្មើសជាក់ស្តែងលុះត្រាតែលោក "ខ" ឬ មន្ត្រីដែលមានសមត្ថកិច្ចបានទៅឃើញលោក "ក" ដែលជាអ្នកខ្ចីម៉ូតូកំពង់តែលក់ម៉ូតូ ឬបញ្ចាំម៉ូតូដែលជាវត្ថុតាង ទើបអាចសន្និដ្ឋានថាជាបទល្មើសជាក់ស្តែង។ ប៉ុន្តែយើងគួរពិចារណាដែរថាតើពេលដែលលោក "ខ" ដែលជាម្ចាស់ម៉ូតូពេលគាត់ប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ឱ្យតាមចាប់ខ្លួនលោក "ខ" ដែលជាអ្នកខ្ចីម៉ូតូ ឬយ៉ាងណា? មានន័យថាគាត់បានចោទលោក "ក" ពីបទរំលោភលើទំនុកចិត្តស្របតាមមាត្រា៣៩១(និយមន័យនៃការរំលោភលើទំនុកចិត្ត) នៃក្រមព្រហ្មទណ្ឌឬយ៉ាងណា។

ចំពោះដំណើរការរបស់ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌លើករណីនេះ គឺជាការបើកការស៊ើបអង្កេតបឋមដែលស្របទៅតាមមាត្រា១១១ (ការបើកការស៊ើបអង្កេតបឋម)

ដែលមន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋមដោយឯកឯងបាន ប៉ុន្តែត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាដែរស្របទៅតាមមាត្រា៣៧ (អំណាចរបស់ព្រះរាជអាជ្ញា) ផងដែរ។ ដូច្នេះករណីដែលលោក "ខ" ប្ដឹងឱ្យចាប់ខ្លួនលោក "ក" ពីបទល្មើសព្រហ្មទណ្ឌណាមួយបែបនេះគឺជាសកម្មភាពស៊ើបអង្កេតបឋមដោយមន្ត្រីនគរបាយុត្តិធម៌។ ព្រោះជាសកម្មភាពដែលមានការចោទប្រកាន់មុនតាមពាក្យបណ្ដឹងមុនការចាប់ខ្លួន និងវត្ថុតាង។ លើកលែងតែជនរងគ្រោះបានទៅឃើញជនបង្ករ និងវត្ថុតាងមុនពេលដាក់ពាក្យបណ្ដឹង ហើយជនរងគ្រោះឃាត់ខ្លួនជននោះ ឬប្ដឹងមន្ត្រីនគរបាលយុត្តិធម៌ឱ្យមកឃើញជនបង្ករ និងវត្ថុតាងក្នុងពេលតែមួយជានោះទើបសន្មត់ថាជាបទល្មើសជាក់ស្ដែង។ ជាធម្មតាបណ្ដឹងរបស់ជនរងគ្រោះគឺ ជាបណ្ដឹងបរិហារតាងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី ទាមទារសំណងរដ្ឋប្បវេណី និងដាក់ឱ្យបណ្ដឹងអាជ្ញាមានចលនា ករណីដែលបណ្ដឹងនេះធ្វើឡើងនៅចំពោះមុខចៅក្រមស៊ើបសួរ ឬប្ដឹងទៅចៅក្រមស៊ើបសួរ។

# ផ្នែកទី២

# អំណាចមន្ត្រីនគរបាលយុត្តិធម៌ ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិកជាក់ស្ដែង

## កថាខ័ណ្ឌទី១៖ វិធានការស្រាវជ្រាវ

នៅក្នុងដំណាក់កាលស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌ និងអនុលោមតាមមាត្រា៨៩ (វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្ដែង) ដល់មាត្រា៩៥ (ការត្រួតពិនិត្យខាងបច្ចេកទេសឬវិទ្យាសាស្ត្រ)បានផ្ដល់អំណាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ក្នុងកិច្ចនីតិវិធីក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្ដែងដូចតទៅ៖

*ក. វិធានការដំបូង៖*

អនុលោមតាមាត្រា៨៩ (វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែ៖

- ជូនដំណឹងឱ្យព្រះរាជអាជ្ញាភ្លាមៗ៖ មានន័យថា ក្នុងករណីដែលមានបទល្មើសដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវតែរាយការណ៍ដល់ព្រះរាជាអាជ្ញាដែលមានសមត្ថកិច្ច ដើម្បីឱ្យព្រះរាជអាជ្ញាបានទទួលដំណឹងពីបទល្មើសនេះ និងផ្តល់ជាយោបល់ក្នុងករណីបទល្មើសនេះ និងព្រះរាជអាជ្ញាជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផងដែរ ករណីដែលមានបទល្មើសជាបទល្មើសដែលប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ប្រទេសខ្លាំង។ ដែលចាំបាច់ឱ្យជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ធ្វើបែបនេះក្នុងន័យទទួលបាននូវការណែនាំ ឬចំណាត់ការនានាពីក្រសួង។
- មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស និងជាអ្នកធានារ៉ាប់រងលើការរក្សាឱ្យទុកនូវតម្រុយ នៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ និងមានសិទ្ធិហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅណាឆ្ងាយពីកន្លែងប្រព្រឹត្តបទល្មើសរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ មានន័យថា ក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ធ្វើការពិនិត្យបទល្មើសតាមរយៈការរាយការណ៍របស់ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ឬមហាជនជាអាទិ៍មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅកន្លែងដែលបទល្មើសបានប្រព្រឹត្ត និងធ្វើការពិនិត្យ ដើម្បីកំណត់និងសន្និដ្ឋានលើបទល្មើសនេះជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង។

*ខ. ការឆែកឆេរ៖*

អនុលោមតាមមាត្រា៩១ (ការឆែកឆេរ) មិនបានប្បញ្ញត្តិបកស្រាយលើបច្ចេកទេសនៃការឆែកឆេរ ឬការចាប់យកភស្តុតាងនោះទេ។ ការឆែកឆេរក្នុងបរិបទនៃច្បាប់កម្ពុជា ជាការកំណត់ទៅលើចំណុចជាសារវន្តដូចជា៖

ពេលចាប់ផ្តើមឆែកឆេរក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងការឆែកឆេរស្តែងឡើង ដោយមានការអនុញ្ញាតពីព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដើម្បីជាការរាយការណ៍ដើម្បីក្នុងន័យទទួលបានការអនុញ្ញាតឱ្យប្រតិបត្តិការឆែកឆេរបាន។ ក្នុងស្មារតីនៃច្បាប់ដដែលមិនបានធ្វើការបែងចែកប្រភេទនៃកន្លែងនៃការឆែកឆេរដូចជាលំនៅឋាន ក្រុមហ៊ុន ក្នុងរថយន្ត ម៉ូតូ ឬរូបកាយរបស់មនុស្សនោះទេ។ ប៉ុន្តែជាការកំណត់លើអធិប្បតីភាពនៃរូបកាយ និងសិទ្ធិរបស់អ្នកកាន់កាប់ទៅវិញ។ បានន័យថាខណៈណាដែលមន្ត្រីនគរបាលយុត្តិធម៌ផ្តើមធ្វើការឆែកឆេរទាំងឡាយណា ដែលប៉ះពាល់ដល់សិទ្ធិរបស់អ្នកកាន់កាប់ទីកន្លែង រូបកាយឬរថយន្តជាដើម ចាំបាច់ឱ្យមានការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុនសិន។

ចំពោះករណីនៃការឆែកឆេរនេះដែរចំបាច់ ឱ្យមានការយល់ព្រមពីអ្នកកាន់កាប់ទីកន្លែងករណីដែលមាន។ ករណីដែលមិនមានអ្នកកាន់កាប់ទីកន្លែងគឺតម្រូវឱ្យមានសាក្សីពីរអ្នកដែលមិនមែនជាប៉ូលីស កងរាជអាវុធហត្ថដែលចូលរួមប្រតិបត្តិការឆែកឆេរនេះ ដោយសាក្សីត្រូវស្បថតាមប្រពៃណីរបស់ពួកគេ។ ករណីនេះក៏សូមបញ្ជាក់ជូនផងដែរថា ករណីណាក៏ដោយទោះជាការឆែកឆេរលើលំនៅដ្ឋាន តំបន់ណាក្តី រថយន្ត ឬរូបកាយមនុស្សក្តី ប្រសិនបើអ្នកកាន់កាប់រថយន្ត ឬបុគ្គលដែលត្រូវបានឆែកឆេរនោះមិនអនុញ្ញាតឱ្យឆែរឆេរទេ ការឆែកឆេរត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា និងមានសាក្សីពីរអ្នកដែលសាក្សីត្រូវគោរពតាមលក្ខខណ្ឌដូចរៀបរាប់ខាងលើ។

ចំពោះករណីនៃការឆែកឆេរនៃមាត្រា៩១ នៃក្រមនេះមិនមែនជាលក្ខខណ្ឌដែលសិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរដោយគ្មានការអនុញ្ញាតពីព្រះរាជអជ្ញានោះទេ។ ប៉ុន្តែវាជាលក្ខខណ្ឌមួយផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីដែលមានសមត្ថកិច្ចអាចបើកការឆែកឆេរដោយមិនគោរពលើលក្ខខណ្ឌពេលវេលាដូចបានកំណត់ក្នុងច្បាប់នេះ។ បានន័យថាចំពោះការឆែកឆេរក្នុងករណីនៃការស៊ើបអង្កេតបឋមអាចឆែកឆេរបានចាប់ពីមុន០៦ព្រឹក និង

បញ្ចប់មុនម៉ោង១៨ល្ងាច។ ប៉ុន្តែករណីដែលដូច ករណីបទល្មើសជាបទល្មើសជាក់ស្តែងដូចមានចែងក្នុងមានត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ឬករណីដូចមានចែងមាត្រា៨៨ (ចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ក្រមនេះ និងករណីដែលមានសម្រែកឱ្យជួយពីក្នុងកន្លែងណាមួយ ករណីដែលធ្វើការឆែកឆេរនៅទីកន្លែងដែលបើកចំហរដោយសាធារណៈជន ព្រមទាំងកន្លែងដែលជាកន្លែងផលិត រក្សាទុក ជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន។

ចំណុចជាសារវ័ន្តដូចបានរៀបរាប់ខាងលើនេះតម្រូវឱ្យមន្ត្រីគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលក្នុងកំណត់ហេតុនោះមានចុះនូវការអនុញ្ញាត របស់ព្រះរាជអាជ្ញាឱ្យបានលំអិតដូចជាឈ្មោះ និងលេខទូរស័ព្ទរបស់ព្រះរាជអាជ្ញាអនុញ្ញាត ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលព្រះរាជអាជ្ញានេះបានអនុញ្ញាតករណីដែលធ្វើការស្នើសុំដោយផ្ទាល់មាត់។ ករណីដែលមានដីការអនុញ្ញាតត្រូវភ្ជាប់ជាមួយក្រដាស់ដីកានេះដាក់ជាភស្តុតាង និងអត្តសញ្ញាណអ្នកកាន់កាប់ទីកន្លែង ឬសាក្សីឱ្យបានច្បាស់លាស់សម្រាប់ដាក់ចូលសំណុំរឿងបញ្ជូនឱ្យ ព្រះរាជអាជ្ញា។

ប៉ុន្តែក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ បានធ្វើការឆែកឆេរក្នុងកន្លែងមួយចំនួនដែលច្បាប់នេះបានដាក់លក្ខខណ្ឌដែរនោះ នោះមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់គោរពតាម ដូចជាក្នុងករណីធ្វើការឆែកឆេរក្នុងការិយាល័យ ឬក្រុមហ៊ុនមេធាវី មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរបានទេ ទោះជាក្នុងលក្ខខណ្ឌណាក៏ដោយ។ ករណីនេះការឆែកឆេរអាចឆែកឆេរអាចបានដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរនៅចំពោះមុខប្រធានមេធាវី ប្រតិភូរបស់ប្រធានមេធាវី ឬមេធាវីសាមីដែលជាម្ចាស់ទីកន្លែង។ ចំពោះរណីនៃការឆែកឆេរនៃទីកន្លែងដែលជាអាគារសាព័ត៌មាន សហគ្រាសសារព័ត៌មានសរសេរ ឬសោតទស្សន៍វិញ ការឆែកឆេរអាចប្រព្រឹត្តដោយនគរបាលយុត្តិធម៌បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដោយធានាកុំឱ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយ

សារព័ត៌មាន ដោយហេតុមានច្បាប់ស្តីពីសារព័ត៌មាន ដែលជាសិទ្ធិមួយត្រូវបានផ្តល់ឱ្យអ្នកសារព័ត៌មាន និងគ្រឹះស្ថានទាំងនោះ។

ក្នុងកំឡុងពេលនៃការឆែកឆេរមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចសំខាន់មួយទៀត គឺការចាប់យកភស្តុតាង។ តាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មន្ត្រីនគរបាលយុត្តិធម៌ត្រូវចាប់យក និងប្រមូលយកភស្តុតាងដោយគោរពតាមនីតិវិធីដូចជា៖ ១-បិទស្លាកបោះត្រាពេលចាប់យកវត្ថុតាង និងធ្វើកំណត់ហេតុចាប់យក ព្រមទាំងបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់ ២-មន្ត្រីនគរបាលក៏បង្ហាញផងដែរនូវវត្ថុតាងដែលចាប់យកទៅកាន់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់ ព្រមទាំងឱ្យអ្នកកាន់កាប់ទីកន្លែង និងសាក្សីទាំងពីរចុះហត្ថលេខាទទួលស្គាល់ លើរបាយការណ៍ចាប់យកវត្ថុតាងដោយមន្ត្រីនគរបាលយុត្តិធម៌។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំបុគ្គលដែលមានសារៈសំខាន់សម្រាប់រឿងក្តី ឬជនដែលពាក់ព័ន្ធក្នុងរឿងក្តីទៅកាន់អង្គភាពរបស់ខ្លួនចំពោះបុគ្គលគ្រប់រូប ដើម្បីស្តាប់ចម្លើយ ដោយមានកំណត់ហេតុច្បាស់លាស់ផងដែរ។ កំណត់ហេតុត្រូវដកស្រង់ឱ្យបានត្រឹមត្រូវ ទៅតាមសេចក្តីរាយការរបស់បុគ្គលដែលផ្តល់ចម្លើយ។ ដោយមន្ត្រីនគរបាលយុត្តិធម៌ មិនត្រូវសរសេរបន្ថែម ឬបន្ថយសេចក្តីលើកំណត់ហេតុឡើយ។ ជាគោលការណ៍យុត្តិធម៌សម្រាប់អ្នកផ្តល់ចម្លើយ ឬជនសង្ស័យ គ្រប់សន្លឹកនៃកំណត់ហេតុត្រូវតែមានហត្ថលេខា ឬមានផ្តិតស្នាមេដៃរបស់បុគ្គលដែលផ្តល់ចម្លើយទាំងនេះ។ ប៉ុន្តែមុននឹងផ្តិតស្នាមមេដៃ ឬចុះហត្ថលេខា បុគ្គលដែលផ្តល់ចម្លើយត្រូវអានលើកំណត់ហេតុឡើងវិញ និងយល់ច្បាស់ពីកំណត់ហេតុនេះថាពិតជាដូចសេចក្តីដែលខ្លួនបានធ្វើ ឬបានឃើញពិតមែន។ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវអានដោយខ្លាំងៗឱ្យអ្នកផ្តល់ចម្លើយបានស្តាប់ ករណីដែលអ្នកផ្តល់ចម្លើយមិនចេះអក្សរ និងករណីដែលអ្នកផ្តល់មិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែដែលស្របទៅតាមនីតិវិធីច្បាប់។ មន្ត្រីនរគរបាលយុត្តិធម៌ត្រូវកំណត់ចំណាំ

នៅក្នុងកំណត់ហេតុរបស់ខ្លួន ករណីដែលអ្នកផ្តល់ចម្លើយមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ។

ត្រង់ចំណុចនេះ អនុញ្ញាតបញ្ជាក់ជូនដែរថា ព្រះរាជាណាចក្រកម្ពុជាមិនមានច្បាប់ស្តីពីភស្តុតាង ដូចបណ្តាប្រទេសដទៃ ដែលជាហេតុនាំឱ្យប្រទេសយើងពិបាកក្នុងការកំណត់នូវ វិធីសាស្ត្រដែលពិតប្រាកដដើម្បីចាប់យកវត្ថុតាងប្រកបដោយយុត្តិធម៌។ កន្លងមកនៅក្នុងសវនាការនៃតុលាការកម្ពុជា តែងតែមានភាពចម្រូងចម្រាស់គ្នាពីការពិបាកទទួលស្គាល់ ចំពោះការចាប់យកភស្តុតាងពីមន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជានីតិវិធីនៃការសួរចម្លើយជនជាប់ចោទរបស់មន្ត្រីនគរបាលយុត្តិធម៌ជាដើម។ ព្រោះថាក្នុងនីតិវិធីនៃការចាប់យកភស្តុតាងនិងបិទស្លាកលើភស្តុតាងនៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺផ្តល់មោឃៈភាពចំពោះការមិនអនុវត្តតាមនីតិវិធីនេះ ដែលជាហេតុរំលោភសិទ្ធិលោកបុគ្គលដែលត្រូវបានចោទប្រកាន់ជាដើម។ ប៉ុន្តែនីតិវិធីមិនមានចែងក្នុងច្បាប់ស្តីពីនីតិវិធីឱ្យបានច្បាស់ការនោះទេ។ ករណីជាក់ស្តែង មេធាវីការពារក្តីរបស់ជនជាប់ចោទតែងតែ ស្នើសុំឱ្យតុលាការបដិសេធនូវកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ដោយហេតុថាមន្ត្រីនគរបាលយុត្តិធម៌បានសួរសម្លើយកូនក្តីរបស់ខ្លួន ដោយប្រើអំពើហិង្សា (ដូចជាវាយតប់ ដោយមិនបណ្តាលឱ្យមានស្លាកស្នាម យកកូនសោទ្បានចាក់ក្បាលជាដើម) កល្បិច (បោកបញ្ឆោតឱ្យចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើកំណត់ហេតុ ដើម្បីឱ្យឪពុកម្តាយមកយកទៅវិញជាដើម)។ ករណីទាំងនេះតែងតែបដិសេធដោយព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ជាដើម ដោយលោកព្រះរាជអាជ្ញាតែងតែសួរទៅកាន់មេធាវីការពារជនជាប់ចោទវិញថា ហេតុអ្វីមិនស្នើសុំមោឃៈភាពកិច្ចនីតិវិធីតាំងពីដំណាក់កាលស៊ើបអង្កេត ហេតុអ្វីមកស្នើសុំនៅក្នុងដំណាក់កាលថៅក្រមជំនុំជម្រះទៅវិញ។ តើអ្នកគួរពិចារណាទេថា ក្នុងលទ្ធភាពរបស់មេធាវី ឬជនជាប់ចោទអាចមានលទ្ធភាពតតាំង ដោយរកភស្តុតាងមកការពារកូនក្តីរបស់ខ្លួនបានដែរឬទេ។ បើគ្រប់យ៉ាងគឺស្ថិតក្នុងការិយាល័យមន្ត្រីនគរបាលយុត្តិធម៌ ។ ច្បាប់របស់យើងមិនបានចែងឱ្យមានការសួរចម្លើយពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ដោយមានការ

ចូលរួមពីសំណាក់មេធាវី ឬមានសាក្សីនោះទេ។ ដែលជាចំណុចមួយដែលពិបាករកយុត្តិធម៌ឱ្យជនត្រូវចោទ និងជាការរំលោភសិទ្ធិមនុស្ស (សិទ្ធិជនជាប់ចោទ) ករណីដែលមន្ត្រីនគរបាលយុត្តិធម៌មិនគោរពតាមនីតិវិធីផងដែរ។

ក្នុងការចាប់យកភស្តុតាង ឬស្តាប់ចម្លើយបុគ្គលដែលពាក់ព័ន្ធ ឬបុគ្គលដែលមានផលប្រយោជន៍សម្រាប់រឿងក្តីនៃក្រមនេះ ហាក់ដូចជាផ្តល់សមត្ថកិច្ចឱ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកមានសិទ្ធិអំណាចក្នុងការកសាងសំនុំរឿង ដើម្បីដាក់ជូនព្រះរាជាអាជ្ញាដើម្បីធ្វើការចោទប្រកាន់ ដែលជាយន្តការមួយដែលនាំទៅរកភាពអយុត្តិធម៌បាន ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ជាមន្ត្រីដែលធ្វើការ និងមានទំនាក់ទំនងជិតស្និតជាមួយប្រជាពលរដ្ឋក្នុងតំបន់នោះ។ នេះជាចំណុច ខ្វះចន្លោះដែលប្រព័ន្ធច្បាប់កម្ពុជាដែលគួរតែកែតម្រូវ ដើម្បីជៀសឱ្យផុតពីភាពអយុត្តិធម៌សង្គម។

## កថាខ័ណ្ឌទី២៖ ការឃាត់ខ្លួន

អនុលោមតាមមាត្រា៩៦ (ការឃាត់ខ្លួន) នៃក្រមនេះ ការឃាត់ខ្លួនក្នុងករណីនៃបទល្មើសជាក់ស្តែង គឺស្ថិតក្នុងដំណាក់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើការឃាត់ខ្លួនបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើស និងបុគ្គលដែលមានសារៈសំខាន់សម្រាប់បទល្មើស។ ចំពោះការឃាត់ខ្លួនបុគ្គលដែលមានសារៈសំខាន់សម្រាប់បទល្មើសត្រូវគោរពតាមលក្ខខណ្ឌដូចជា៖ ១-ករណីដែលបុគ្គលដែលអាចផ្តល់ព័ត៌មានបដិសេធមិនព្រមផ្តល់ព័ត៌មាន ២-មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញាដើម្បីធ្វើការឃាត់ខ្លួន។

កាឃាត់ខ្លួនមានថិរវេលា៤៨ (សែសិបប្រាំបី)ម៉ោង បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ និងបញ្ជូនគ្រប់ភស្តុតាងពីការឃាត់ខ្លួនឱ្យព្រះរាជអាជ្ញា។ ថិរវេលានៃការឃាត់ខ្លួនអាចពន្យាបាន២៤ (ម្ភៃបួន)ម៉ោង ដោយមិនគិតពីការដឹកជញ្ជូន ដោយគោរពតាមលក្ខខណ្ឌដូចជា៖ ១-បទល្មើសជាឧក្រិដ្ឋ កាលណាមានតម្រុញបង្ហាញពីពិរុទ្ធភាពលើបុគ្គលដែលឃាត់

ខ្លួន និងចាំបាច់ដើម្បីការប្រព្រឹត្តទៅដោយល្អនៃការស៊ើបអង្កេត ២-មានការផ្ទៀងផ្ទាត់មូលក-ភាពពីព្រះរាជអាជ្ញា។

ការពន្យាពេលនៃការឃាត់ខ្លួន មិនត្រូវបានពន្យាពេលបានទេករណីជនសង្ស័យជាអនីតិជន។ ការពន្យាពេលត្រូវគោរពតាមលក្ខខណ្ឌអាយុ និងលក្ខខណ្ឌទៅតាមទោសទណ្ឌដូចតទៅៈ ១-ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំ មិនត្រូវឃាត់ខ្លួនលើសពី៣៦ម៉ោងឡើយ ២-ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី១៤ឆ្នាំ ទៅក្រោម១៦ឆ្នាំមិនត្រូវឃុំខ្លួនលើសពី២៤ម៉ោងឡើយ ៣-ចំពោះបទឧក្រិដ្ឋ អនីតិជនមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ មិនត្រូវឃាត់ខ្លួនលើសពី៤៨ម៉ោងឡើយ ៤-ចំពោះបទជ្ឈិម អនីតិជនអាយុ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ មិនត្រូវបានឃាត់ខ្លួនលើសពី៣៦ម៉ោងឡើយ។ ៥-អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនត្រូវបានឃាត់ខ្លួនឡើយ។

ពេលដែលមានការឃាត់ខ្លួនរបស់បុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់បុគ្គលនោះភ្លាម ពីក្តីសម្រេចរបស់ខ្លួន មូលហេតុនៃការឃាត់ខ្លួន និងសិទ្ធិការពារខ្លួន (មានមេធាវី)ជាដើម។ ការឃាត់ខ្លួននេះត្រូវមានកំណត់ហេតុ ដែលមានចុះដូចជាៈ ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួន អត្តសញ្ញាណបុគ្គលដែលឃាត់ខ្លួន មូលហេតុនៃការឃាត់ខ្លួន ថ្ងៃ ខែ ឆ្នាំ និងម៉ោងឃាត់ខ្លួន ការឱ្យដំណឹងពីសិទ្ធិការពារខ្លួន និងឈ្មោះរបស់អ្នកបកប្រែបើមាន។ កំណត់ហេតុឃាត់ខ្លួនត្រូវមានចុះហត្ថេខា ឬផ្តិតមេដៃរបស់ជនដែលឃាត់ខ្លួន ករណីដែលមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានកំណត់ហេតុដោយខ្លាំងៗឱ្យស្តាប់។ ករណីដែលជនសង្ស័យមិនព្រមចុះហត្ថលេខ ឬផ្តិតស្នាមមេដៃ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។ កំណត់ហេតុនេះ ត្រូវភ្ជាប់ជាមួយសំណុំរឿង។

ក្នុងពេលឃាត់ខ្លួនបាន២៤ម៉ោងកន្លងផុតទៅ (ចាប់គិតពីពេលដែលនាំជនសង្ស័យមកការិយាល័យកងរាជអាវុធហត្ថ ឬទីស្នាក់ការនគរបាល) បន្ទាប់ពីការឃាត់ខ្លួនជនសង្ស័យអាចសុំសន្ទនាជាមួយមេធាវី ឬជនដែលខ្លួនបានជ្រើសរើសកុំឱ្យតែជននោះមានទាក់ទងជាមួយ

រឿងក្តី ក្នុងរយៈពេល៣០នាទីដោយធានាការម្ងាត់ និងជននោះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរបាន។

ក្នុងលក្ខខណ្ឌនៃការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយទាំងអស់ទៅដល់ឪពុក ម្តាយ អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជន។

ក្នុងពេលឃាត់ខ្លួនព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌សុំឱ្យគ្រូពេទ្យពិនិត្យ ផ្ទៀងផ្ទាត់ស្ថានសុខភាពបុគ្គលដែលឃាត់ខ្លួន ថាសមស្របនឹងឃាត់ខ្លួនដែរឬទេ។ ប្រសិនជាគ្រូពេទ្យពិនិត្យឃើញថាបុគ្គលនេះមិនសមនឹងឃាត់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលភ្ជាប់ជាមួយសំណុំរឿង។ មន្ត្រីនគរបាលយុត្តិធម៌ចុះនិទ្ទេសលើកំណត់ហេតុពីឈ្មោះរបស់គ្រូពេទ្យ ថ្ងៃ ខែ ឆ្នាំ និងម៉ោងពិនិត្យសុខភាព។ ព្រះរាជអាជ្ញាក៏អាចចុះទៅកន្លែងឃាត់ខ្លួនផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់កិច្ចការឃាត់ខ្លួននេះ។

នៅក្នុងទីស្នាក់ការនៃកន្លែងឃាត់ខ្លួនត្រូវមានបញ្ជីឃាត់ខ្លួន។ គ្រប់ការឃាត់ខ្លួនទាំងអស់ត្រូវចុះនូវៈ ១-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន ២-អត្តសញ្ញាណរបស់បុគ្គលដែលឃាតខ្លួន ៣-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន ៤-ឈ្មោះ និងឋានៈចៅក្រមដែលអនុញ្ញាតឱ្យឃាត់ខ្លួន ៥-ឈ្មោះគ្រូពេទ្យដែលពិនិត្យ ៦-ក្តីសម្រេចរបស់អាជ្ញាធរតុលាការពេលផុតកំណត់ឃាត់ខ្លួន។ បញ្ជីឃាត់ខ្លួននេះត្រូវកាន់កាប់ជាប្រចាំ។

បើទោះជាមានការធ្វើកំណត់ហេតុនីមួយៗក្តី ក៏មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន។ កំណត់ហេតុសរុបនៃការឃាត់ខ្លួនគឺជាកំណត់ហេតុដែលសរសេរបញ្ចូលទាំងអស់នូវកំណត់ហេតុកន្លងមកជាអាទ៍ដូចជា៖ ១-ឈ្មោះ និងឋានៈមន្ត្រីនគរបាល

ដែលឃាត់ខ្លួន ២-អត្តសញ្ញាណជនដែលឃាត់ខ្លួន ៣-មូលហេតុនៃការឃាត់ខ្លួន ៤-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមឃាត់ខ្លួន ៥-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា ៦-បែបបទនៃការជូនដំណឹងពីការឃាត់ខ្លួនអនីតិជន ៧-ឈ្មោះគ្រូពេទ្យដែលពិនិត្យ ៨-អត្តសញ្ញាណជនដែលសន្ទនាជាមួយពេលឃាត់ខ្លួន ៩-ឈ្មោះ និងឋានៈថៅក្រមអនុញ្ញាតឱ្យឃាត់ខ្លួន ១០-ថេរៈវេលានៃការស្ដាប់ចម្លើយនីមួយៗ និងថេរៈវេលាសម្រាកបន្ទាប់ពីស្ដាប់ចម្លើយ ១១-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលឃាត់ខ្លួន ១២-ប្រភេទក្ដីសម្រេចរបស់អាជ្ញាធរតុលាការពេលបញ្ចប់ការឃាត់ខ្លួន ១៣-លក្ខខណ្ឌប្រព្រឹត្តទៅនៃការឃាត់ខ្លួន និងឧប្បត្តិហេតុបើសិនមាន។ កំណត់ហេតុសរុបនៃការឃាត់ខ្លួននេះត្រូវបញ្ជូនជាមួយសំណុំរឿង។

## កថាខណ្ឌទី៣៖ ការបញ្ជូនខ្លួន

នៅពេលផុតកំណត់រយៈពេលឃាត់ខ្លួន (៤៨ម៉ោង និងបន្តបាន២៤ម៉ោង ដោយមិនគិតលក្ខខណ្ឌដឹកជញ្ជូន) បុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវ៖ ១-បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ២-ដោះលែងឱ្យមានសេរីភាព។ ដែលជាក្ដីសម្រេចរបស់ព្រះរាជអាជ្ញា។

បុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនភ្លាមទៅមុខព្រះរាជអាជ្ញានៅថ្ងៃតែមួយ ប៉ុន្តែអាចពន្យាពេលបានដោយព្រះរាជអាជ្ញា នៅខណៈដែលមានមូលហេតុពិសេសដូចជាការពិបាកនៃការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូនជាដើម។ មូលហេតុនៃ ការពន្យាពេលនេះត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា។ ក្នុងករណីណាក៏ដោយការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវធ្វើឡើងដោយឆាប់បំផុតតាមតែអាចធ្វើទៅបាន។

## កថាខណ្ឌទី៤៖ វិធាននៃការស៊ើបអង្កេតជាក់ស្ដែង

នៅក្នុងតំណាក់ការនៃមន្ត្រីនគរបាលយុត្តិធម៌ ពុំអាចបង្គាប់ឱ្យធ្វើការស្ដាប់ ឬថតសម្លេងសន្ទនាតាមទូរស័ព្ទ ឬតាមគ្រប់មធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬតាមអ៊ីនធើណែតបានឡើយ។

នៅខណៈដែលមន្ត្រីនគរបាលកំណត់ ក្នុងកំណត់ហេតុរបស់ខ្លួនថាបទល្មើសជាក់ស្តែង ដោយសំអាងមូលហេតុច្បាប់(មាត្រា៨៦ និយមន័យបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែងជាអាទិ៍)។ ចាប់ពីថ្ងៃផ្តើមការស៊ើបអង្កេតនេះ រយៈពេល៧ (ប្រាំពីរ)ថ្ងៃ ជាបន្តបន្ទាប់ ប៉ុន្តែនៅតែមិនអាចរកឃើញជនសង្ស័យនោះអនុភាពនៃបទល្មើសជាក់ស្តែងនឹងត្រូវបញ្ចប់។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំយោបល់ពីព្រះរាជអាជ្ញា ព្រោះថាវាឈានចូលអនុភាពនៃការស៊ើបង្កេតបឋមវិញ។

ក្រោយពីការស៊ើបអង្កេតបានបញ្ចប់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ ព្រមទាំងខ្លួនបុគ្គលដែលសង្ស័យទៅជាមួយផង។ កំណត់ហេតុនោះមានចុះដូចជា ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ អង្គភាពរបស់មន្ត្រីនោះ កាលបរិច្ឆេទ។ គ្រប់ទំព័រកំណត់ហេតុត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ (អ្នកធ្វើកំណត់ហេតុ)។ ករណីដែលមានការឆូត ឬលុប និងការយោងត្រូវបញ្ជាក់យល់ព្រមដោយហត្ថលេខរបស់មន្ត្រីនគរបាលយុត្តិធម៌លើរឹមទំព័រ។ កំណត់ហេតុនេះដែរ ត្រូវចុះអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ។ រាល់កិច្ចនីតិវិធីដែលបានអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ និងត្រូវបានមោឃៈភាពចោល ក្នុងករណីដែលមន្ត្រីនគរបាលរូបនេះ មិនគោរពតាមវិធាននៃច្បាប់នេះ។ កិច្ចនីតិវិធីដែលត្រូវគោរពតាម បើមិនគោរពនឹងនាំមកមោឃៈភាពនៃកិច្ចនីតិវិធីមានដូចជា៖ មាត្រា៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ) មាត្រា៩១ (ការឆែកឆេរ) មាត្រា៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) មាត្រា៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) មាត្រា៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង) មាត្រា៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកវិទ្យា ឬវិទ្យាសាស្ត្រ) មាត្រា៩៦ (ការឃាត់ខ្លួន) មាត្រា៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន) មាត្រា៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) មាត្រា៩៩ (ជំនួយរបស់គ្រូពេទ្យនៅពេលឃាត់ខ្លួន) មាត្រា១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) មាត្រា១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍) មាត្រា១០៦ (ថេរៈវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង) និងមាត្រា ១០៨ (និទ្ទេសដែលត្រូវចុះក្នុងកំណត់ហេតុ) នៃក្រមនេះ។

កំណត់ហេតុដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើត្រូវចាត់ទុកជាបន្ទាល់ "ឯកសារដើម" ដែលត្រូវជឿទុកចិត រហូតមានភស្តុតាងផ្ទុយពីនេះមកអះអាង។ ភស្តុតាងផ្ទុយអាចបញ្ជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយដែលស្របច្បាប់។ ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង។

# ជំពូកទី៣

# ការស៊ើបអង្កេតបឋម

## ផ្នែកទី១

## ការស៊ើបអង្កេតបឋម

### កថាខណ្ឌទី១៖ និយមន័យទូទៅ

ការស៊ើបអង្កេតបឋម គឺសំដៅដល់ការស៊ើបអង្កេតលើបទល្មើសទាំងឡាយ ដែលមិនមានតម្រុញបង្ហាញថាជាបទល្មើសជាក់ស្តែង។ ការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិក្នុងការស៊ើបអង្កេតដោយឯកឯង ឬតាមសំណូមពររបស់ព្រះរាជអាជ្ញា ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ការបើកការស៊ើបអង្កេតដោយឯកឯង វាហាក់ដូចជាផ្តល់អំណាចឱ្យមន្ត្រីនគរបាលយុត្តិធម៌មានស្វ័យសម្រេចលើការស្រាវជ្រាវនេះ។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែងមិនបែបនេះទេ ទោះយ៉ាងណាក្តីមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវគោរពតាមការបញ្ជារបស់ព្រះរាជាអាជ្ញា។ ព្រោះថាក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៧ (អំណាចរបស់ព្រះរាជអាជ្ញា) បានផ្តល់អំណាចឱ្យព្រះរាជអាជ្ញាជាអ្នកដឹកនាំ សម្របសម្រួល មន្ត្រីនគរបាលយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ។ ដូច្នេះតាមការអនុវត្តមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែសូមយោបល់ពីព្រះរាជអាជ្ញាជាមុន មុននឹងធ្វើសកម្មភាពស៊ើបអង្កេតណាមួយ។

## កថាខណ្ឌទី២៖ វិធានអនុវត្តចំពោះការស៊ើបអង្កេតបឋម

ចំពោះវិធានដែលត្រូវអនុវត្តក្នុងការស៊ើបអង្កេតបឋម គឺអនុវត្តដូចទៅនឹងមាត្រាដែលមានចែងនៅក្នុងជំពូកខាងលើ ដែលនិយាយពីវិធានការស៊ើបអង្កេតជាក់ស្តែងមកអនុវត្តដូចគ្នា។ ករណីដូច មាត្រា៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ) មាត្រា៩៥ (ការត្រួតពិនិត្យ ខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) មាត្រា១០៥ (ការហាមឃាត់មិនឱ្យ ស្លាប់ដោយឯកឯងជាអាទិ៍) មាត្រា១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា) មាត្រា១០៨ (និទ្ទេសដែលត្រូវចុះក្នុងកំណត់ហេតុ) ត្រូវយកមកអនុវត្តក្នុងការស៊ើបអង្កេតបឋម។

## កថាខណ្ឌទី៣៖ ការឆែកឆេរ

ក្នុងករណីនៃការស៊ើបអង្កេតបឋមក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ដោយគោរពតាមគោលការបីគឺ៖ ១-គោលការណ៍យល់ព្រម ២-គោលការណ៍បដិសេធ និង៣-គោលការណ៍លក្ខខណ្ឌនៃពេលវេលា។

១. គោលការណ៍យល់ព្រមពីសំណាក់អ្នកកាន់កាប់ទីកន្លែង៖ ករណីដែលមានការយល់ព្រមពីសំណាក់អ្នកកាន់កាប់ទីកន្លែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន។ ការយល់ព្រម គឺត្រូវសេរសេរជាលិខិតលាយលក្ខណ៍អក្សរ ដោយផ្ទាល់ដៃរបស់អ្នកកាន់កាបទីកន្លែង។ ករណីដែលអ្នកកាន់កាប់ទីកន្លែង មិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសរសេរឱ្យច្បាស់លាស់ក្នុងកំណត់ហេតុ ថាអ្នកកាន់កាប់ទីកន្លែងដែលឆែកឆេរមិនចេះអក្សរ ហើយយល់ព្រមឱ្យធ្វើការឆែកឆេរ។ ដូច្នេះការឆែរឆេរដែលមានការយល់ព្រមពីអ្នកកាន់កាប់ទីកន្លែង មន្ត្រីនគរបាលយុត្តិធម៌មិនចាំបាច់មានការយល់ព្រមពីព្រះរាជអាជ្ញាទេ។

២. គោលការណ៍បដិសេធពីអ្នកកាន់កាប់ទីកន្លែង៖ ករណីដែលអ្នកកាន់កាប់ទីកន្លែបានបដិសេធ ឬមិនមានវត្តមាននៅកន្លែងឆែរឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញដីការអនុញ្ញាតឱ្យឆែកឆេរតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាដឹកនាំ

កម្លាំងសមត្ថកិច្ចធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ករណីដែលមិនមានអ្នកកាន់កាប់ទីកន្លែង ការឆែកឆេរត្រូវធ្វើចំពោះមុខសាក្សីពីរនាក់ ដែលចាត់តាំងដោយព្រះរាជអាជ្ញា សាក្សីជាបុគ្គលដែលមិនមែនជាមន្ត្រីដែលចូលរួមឆែកឆេរ។

៣.គោលការណ៍លក្ខខណ្ឌពេលវេលា៖ មន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តើមការឆែកឆេរមុនម៉ោង៦ (ប្រាំមួយ)ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី) ល្ងាយនោះទេ។

ដោយឡែកការបិទស្លាក និងការបោះត្រាលើវត្ថុតាងពេលចាប់យកភស្តុតាង ត្រូវអនុលោមតាមមាត្រា៩១ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៩។

ក្នុងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបឋម ចាត់ទុកជាបន្ទាល់ "ឯកសារដើម" នៅក្នុងសវនការ រហូតមានភស្តុតាងផ្ទុយមកជំនួស។ ចៅក្រមអាចធ្វើមូលវិចារណ៍ដោយសេរីលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ បានក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមបាន។

# ជំពូកទី៤

# ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

## ផ្នែកទី១

## ប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត ទាំងបទល្មើសជាក់ស្តែង ឬការស៊ើបអង្កេតបឋមក្តី បន្ទាប់ពីការសិក្សាលើវត្ថុដែលចាប់យក ឬទ្រព្យដែលចាប់យករួចមក អាជ្ញាធរតុលាការត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ក្នុងករណី និងលក្ខខណ្ឌដូចតទៅៈ

## កថាខណ្ឌទី១៖ អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ

ព្រះរាជអាជ្ញា អាចបង្គាប់ឱ្យនគរបាលយុត្តិធម៌ប្រគល់វត្ថុដែលចាប់យកពេលធ្វើការស៊ើបអង្កេត ករណីដែលវត្ថុនោះមិនមានសារៈសំខាន់ក្នុងការបង្ហាញការពិត និងមិនមានការជំទាស់ពីអ្វីពិតប្រាកដ។ ប៉ុន្តែវត្ថុដែលនាំឱ្យមានគ្រោះថ្នាក់ដូចជាអាវុធជាតិផ្ទុះដែលកាន់កាប់ខុសច្បាប់ មិនត្រូវបានប្រគល់ឱ្យវិញនោះទេ ដោយត្រូវរឹបអូសទុកជាសម្បត្តិរបស់រដ្ឋ។ ករណីមិនព្រមប្រគល់ឱ្យតាមពាក្យប្តឹង អ្នកប្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍បាន។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាគ្មានសមត្ថកិច្ចប្រគល់ទេ កាលណាការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ព្រោះផុតសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងអង្គព្រះរាជអាជ្ញា តែជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះវិញ រហូតការស៊ើបសួរបានបញ្ចប់ដោយដីកាសម្រេចលើកលែងការចោទប្រកាន់។

នៅពេលសម្រេចក្តីរបស់តុលាការ តែមិនបានសម្រេចពីការប្រគល់វត្ថុឱ្យម្ចាស់ដើមវិញទេ ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចប្រគល់ឱ្យម្ចាស់ដើមវិញតាមករណីនិមួយៗ បើកម្មសិទ្ធិនៃវត្ថុមិនជំទាស់ទេនោះ។